ADVANCING EDUCATION SAFELY SY 2020 -2021

# ឆ្នាំសិក្សា ២០២០-២០២១

# វត្តមានអវត្តមាន និង ការដាក់ពិន្ទុ




ឆ្នាំសិក្សា ២០២០-២០២១ ចាប់ផ្តើមនៅថ្ងៃពុធ ទី ២ ខែកញ្ញា ដោយសិស្ស ថ្នាក់មត្តេយ្យ ដល់ថ្នាក់ទី ១២ ទាំងអស់រៀនតាមកុំព្យូទ័រ ៥ ថ្ងៃ ក្នុងមួយសប្តាហ៍ ជាមួយគ្រូនៅសាលាដែលពួកគេបានចុះឈ្មោះ។ គ្មានការសង្ស័យទេថា ការសិក្សាតាមកុំព្យូទ័រនឹង មើលទៅ និង មានអារម្មណ៍ថា ខុសគ្នាពីនិទាឃរដូវមុន។ យើងបានខិតខំធ្វើឱ្យការសិក្សាតាមកុំព្យូទ័រនៅឆ្នាំនេះ ក្លាយជាបទពិសោធន៍ដ៏ល្អសម្រាប់សិស្សានុសិស្ស។ ផ្អែកលើមតិយោបល់របស់លោកអ្នក សិស្សានុសិស្សនឹងមានឱកាសកាន់តែច្រើនក្នុងការសហការជាមួយមិត្តភក្តិរបស់ពួកគេ ចូលរួមក្នុងការសិក្សាផ្អែកលើគម្រោងកិច្ចការ ធ្វើឱ្យស៊ីជម្រៅ និង ប្រើចំណេះដឹង ជាមួយនឹងបទពិសោធន៍នៃជីវិតរស់នៅ និង បង្កើនពេលវេលារបស់ពួកគេជាមួយគ្រូ។ យើងក៏បានផ្តល់ការបណ្តុះបណ្តាលបន្ថែមដល់លោកគ្រូអ្នកគ្រូរបស់យើង ដើម្បីឱ្យពួកគាត់អាចជួយដល់តម្រូវការ នៃមនោសញ្ចេតនាផ្នែកសង្គមរបស់សិស្ស ឱ្យបានកាន់តែប្រសើរឡើង និង ផ្តល់ឱ្យមានការចូលរួមកាន់តែច្រើនក្នុងការបង្ហាត់បង្រៀនតាមកុំព្យូទ័រ។

**វត្តមានអវត្តមាន និង ការដាក់ពិន្ទុ** គឺជាផ្នែកមួយដ៏សំខាន់នៃវិធីដែលយើងបង្កើតបរិយាកាសសិក្សាតាមកុំព្យូទ័រ ដែលជាវិធីធ្វើឱ្យ គ្រូ និង សិស្ស រក្សាទំនាក់ទំនងរឹងមាំប្រចាំថ្ងៃ ហើយសិស្សទទួលបាន ជំនួយ និង ការលួងលោម ដូចពេលដែលពួកគេធ្លាប់ទទួលពីសាលារៀន។ **នេះជាអ្វីដែលគេអាចរំពឹងទុក និងជាវិធីដែលលោកអ្នកអាចជួយដល់ឆ្នាំសិក្សាប្រកបដោយជោគជ័យ សម្រាប់កូនរបស់លោកអ្នក៖**

**វត្តមានអវត្តមាន**

ទោះបីជាសាលាបង្រៀនតាមកុំព្យូទ័រទាំងស្រុងក៏ដោយ ក៏គេរំពឹងថាសិស្សនឹងចូលរួមពេញមួយថ្ងៃ និង គ្រប់ម៉ោង នៃថ្ងៃសិក្សានីមួយៗ។

**ចុចចូលទាន់ពេលវេលា ជារៀងរាល់ថ្ងៃ**

យើងរំពឹងថាសិស្សានុសិស្សនឹងចុចចូលរៀន ដូចដែលយើងរំពឹងថាសិស្សានុសិស្សចូលក្នុងថ្នាក់រៀនដូច្នោះដែរ។ ជួយកូនរបស់លោកអ្នកឱ្យចុចចូលក្នុងថ្នាក់របស់គាត់ឱ្យទាន់ពេលវេលា ជារៀងរាល់ថ្ងៃ គឺជាចំណុចមួយដ៏សំខាន់បំផុតដែលលោកអ្នកអាចធ្វើ ដើម្បីជួយគាត់ឱ្យទទួលបានជោគជ័យ។ ការស្រាវជ្រាវបានបង្ហាញថា ក្មេងដែលមានវត្តមានល្អ ច្រើនតែចេះអាន ដល់ ឬ ខ្ពស់ជាង កម្រិតថ្នាក់ ហើយទទួលបានជោគជ័យ នៅក្នុង និង ក្រៅ សាលា។

**ការដាក់ពិន្ទុ**

ដូចគ្នានឹងឆ្នាំសិក្សាធម្មតាដែរ គ្រូរបស់យើងនឹង ធ្វើការវាយតម្លៃ និង ដាក់ពិន្ទុ ដល់កិច្ចការសាលារបស់កូនលោកអ្នក ពេញមួយឆ្នាំ។ ចំណាយពេលដើម្បីពិនិត្យមើលកិច្ចការសាលារបស់កូនលោកអ្នកជារៀងរាល់ថ្ងៃ ហើយត្រូវធ្វើយ៉ាងណាឱ្យគាត់ប្រគល់កិច្ចការរបស់កាត់ឱ្យទាន់ពេលវេលា។ លោកអ្នកអាចមើលគោលការណ៍ណែនាំតាមកម្រិតថ្នាក់នៅ bit.ly/sdpgradeguide ។

**វត្តមានអវត្តមាន និង ពិន្ទុ នៅចុងម្រាមដៃរបស់លោកអ្នក**

លោកអ្នកអាចមើល ពិន្ទុ ពិន្ទុនៃការប្រឡង ឯកសារវត្តមានអវត្តមាន និង អ្វីៗជាច្រើនទៀត របស់កូនលោកអ្នក បានគ្រប់ពេលវេលា តាមរយៈគណនីទំព័រវ៉ិបសៃរបស់ មាតាបិតា និង ក្រុមគ្រួសារ។ ដើម្បីស្វែងយល់បន្ថែម និង ចុះឈ្មោះ សូមចូលមើលវ៉ិបសៃ signup.philasd.org ។

**ត្រូវការជំនួយបន្ថែមផ្នែកវត្តមានអវត្តមាន?**

យើងខ្ញុំនៅទីនេះដើម្បីជួយលោកអ្នក។ ទាក់ទងទៅគ្រូរបស់កូនលោកអ្នក ឬ ផ្ញើអ៊ីម៉ែលទៅការិយាល័យ វត្តមានអវត្តមាន និង ការគេចសាលា attendanceandtruancy@philasd.org ដើម្បីសុំជំនួយ បើសិនជាមានឧបស័គ្គអ្វីមួយរារាំងមិនឱ្យកូនរបស់លោកអ្នកចូលរួមសិក្សាបានជារៀងរាល់ថ្ងៃ។

**យោបល់ និង ប្រភពជំនួយ**

សូមមើលវ៉ិបសៃ philasd.org/chromebooks សម្រាប់ការណែនាំដែលមានប្រយោជន៍អំពីវិធីចុចចូល ថ្នាក់រៀនហ្គូហ្គោល និង វិធីប្រើ កុំព្យូទ័រក្រូមប៊ុករបស់កូនលោកអ្នក។